## ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ០១ ន.ស.៩៤

# ព្រះរាជក្រម

**យើង**

**ព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស**

**អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើនៅថ្ងៃទី២៤-៩-១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១-១១-១៩៩៣
- គណៈរដ្ឋមន្ត្រីបានយល់ព្រមដល់

---

## <u>ប្រកាសអោយប្រើ</u>

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នាថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការដាក់ក្រុម < កម្ពុជាប្រជាធិបតេយ្យ > អោយនៅក្រៅច្បាប់ ដូចមានសេចក្តីទៅនេះ ៖

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

# ស្តីពី

# ការដាក់ក្រុម

# " កម្ពុជាប្រជាធិបតេយ្យ "

# អោយនៅក្រៅច្បាប់

---

ព.ស ២៥៣៨ គ.ស ១៩៩៤

# ច្បាប់

## ស្ដីពី

## ការដាក់ក្រុម

## « កម្ពុជាប្រជាធិបតេយ្យ »

## ឱ្យនៅក្រៅច្បាប់

### រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា

- ដោយយល់ឃើញថា កិច្ចព្រមព្រៀងនៅទីក្រុងប៉ារីសនាថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩១ ស្ដីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះនៅកម្ពុជាដែលក្រុម « កម្ពុជាប្រជាធិបតេយ្យ » បានចុះហត្ថលេខាជាមួយហត្ថលេខីខ្មែរបីទៀត តម្រូវឱ្យក្រុម « កម្ពុជាប្រជាធិបតេយ្យ » ក៏ដូចជាហត្ថលេខីបីទៀតអនុវត្តបទបញ្ញត្តិទាំងប៉ុន្មានសម្រាប់នាំមកនូវសន្តិភាពនិងការផ្សះផ្សាជាតិ ។

- ដោយជាក់ស្ដែង ក្រុម « កម្ពុជាប្រជាធិបតេយ្យ » មិនព្រមអនុវត្តបទបញ្ញត្តិសំខាន់ៗនៃកិច្ចព្រមព្រៀងខាងលើ ហើយជាពិសេសរំលោភលើមាត្រាដែលទាមទារ :
  - ✦ ឱ្យគោរពបទឈប់បាញ់
  - ✦ ឱ្យអនុញ្ញាតឱ្យមន្ត្រីនិងបុគ្គលិករបស់អាជ្ញាធរបណ្ដោះអាសន្ននៃអង្គការសហប្រជាជាតិ ( អ.ស.ប ) ចូលទៅក្នុងតំបន់ដែលខ្លួនកាន់កាប់
  - ✦ ឱ្យអនុវត្តការប្រមូលផ្ដុំកម្លាំងប្រដាប់អាវុធរបស់ខ្លួន ដកអាវុធនិងរំសាយកម្លាំងទ័ព
  - ✦ ឱ្យគោរពសិទ្ធិមនុស្សនៅកម្ពុជា

- ដោយឡែកពីការមិនគោរពបទបញ្ញត្តិសំខាន់ៗ ទាំងឡាយខាងលើដែលខ្លួនជាហត្ថលេខី ក្រុម « កម្ពុជាប្រជាធិបតេយ្យ » ឈ្លានពានដោយប្រដាប់អាវុធទៅលើមន្ត្រីនិងបុគ្គលិករបស់អាជ្ញាធរបណ្ដោះអាសន្ននៃ អ.ស.ប ទៅលើមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជានិងទៅលើអាយុជីវិតរបស់ប្រជារាស្ត្រកម្ពុជាដោយមិនរើសមុខ ។

- ដោយក្រុម « កម្ពុជាប្រជាធិបតេយ្យ » មិនព្រមចុះឈ្មោះគណៈបក្សរបស់ខ្លួនក្នុងបញ្ជីគណៈបក្សនយោបាយសម្រាប់ចូលរួមក្នុងការបោះឆ្នោតតាមបញ្ញត្តិនៃច្បាប់បោះឆ្នោតរបស់ អ.ស.ប សម្រាប់កម្ពុជា ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩២ និងមិនព្រមចូលរួមក្នុងកិច្ចអ្វីៗទាំងអស់ ដែលច្បាប់បានបញ្ញត្តិ ដើម្បីឱ្យក្រុមខ្លួនទៅជាគណៈបក្សនយោបាយត្រឹមត្រូវពេញលក្ខណៈច្បាប់ ។

- ដោយតាំងពីពេលបោះឆ្នោតឆ្នាំ ១៩៩៣ រៀងរហូតមក ក្រុម «កម្ពុជាប្រជាធិបតេយ្យ» បានប្រព្រឹត្តជាបន្តបន្ទាប់នូវ ឧក្រិដ្ឋកម្ម ភេរវកម្មនិងអំពើប្រល័យពូជសាសន៍ ដែលជាចរិតពិតរបស់ក្រុមខ្លួន តាំងពីក្រុមខ្លួនឡើងយកអំណាចកាន់កាប់នៅខែ មេសា ឆ្នាំ ១៩៧៥ ជម្លៀសប្រជារាស្ត្រ ចាប់ខ្លួន សម្លាប់រង្គាល ហើយក្រោយមក លួចប្លន់ ដាក់មីនពាសវាល ពាសព្រៃ គ្រប់ទិសទី បំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈនិងទ្រព្យសម្បត្តិឯកជន ដឹកនាំកាប់សម្លាប់ប្រជារាស្ត្រ វាយទន្ទ្រានយកទឹកដីជាតិកាន់កាប់ដោយខុសច្បាប់និងលក់សម្បត្តិទ្រព្យធម្មជាតិដោយរំលោភទៅលើអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា ។

ដោយក្រុម « កម្ពុជាប្រជាធិបតេយ្យ » បានរំលោភលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសលើបទបញ្ញត្តិនៃ :

មាត្រា ៣ ដែលចែងថា « ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋដែលមិនអាចបំបែកបាន »

មាត្រា ៤៩ ដែលចែងថា « ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់ » « ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ »

មាត្រា ៥០ ដែលចែងថា « ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវគោរពគោលការណ៍អធិប_តេយ្យជាតិនិងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស »

«ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវគោរពទ្រព្យសម្បត្តិសាធារណៈនិងកម្មសិទ្ធស្របច្បាប់របស់ឯកជន »

មាត្រា ៥២ ដែលចែងជារួមថា « រាជរដ្ឋាភិបាលកម្ពុជាប្ដេជ្ញារក្សាឯករាជ្យអធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយផ្សះផ្សាជាតិ ដើម្បីការពារឯកភាពជាតិ ការពារនីត្យានុកូលភាព ធានាសណ្ដាប់ធ្នាប់និងសន្តិសុខសាធារណៈ » ។

• ដោយក្រុម « កម្ពុជាប្រជាធិបតេយ្យ » មិនព្រមទទួលយកសេចក្ដីអំពាវនាវជាបន្តបន្ទាប់ឱ្យមកចូលរួមក្នុងដំណើរការផ្សះផ្សាជាតិ ប្រកាសឡើងដោយអាជ្ញាធរអ៊ុនតាក់ ដោយថ្នាក់ដឹកនាំកាតិងទៀត ហើយក្រោយមកនេះ ដោយព្រះករុណាជាអម្ចាស់ជីវិតលើត្បូងនិងដោយរាជរដ្ឋាភិបាលដែលកើតចេញពីការបោះឆ្នោតដោះស្រាយបញ្ហាកម្ពុជា ។

• ដោយយល់ឃើញថា មេដឹកនាំនៃក្រុម «កម្ពុជាប្រជាធិបតេយ្យ» មិនអាចយកកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្ដីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះនៅកម្ពុជាធ្វើជាខែលខាងច្បាប់សម្រាប់លាក់បំបាំងយករួចខ្លួនពីការទទួលខុសត្រូវរបស់ពួកខ្លួន ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្ម ភេរវកម្មនិងអំពើប្រល័យពូជសាសន៍ចាប់តាំងពីពេលរបប ប៉ុល ពត ដណ្ដើមកាន់អំណាចនៅឆ្នាំ ១៩៧៥_១៩៧៨ ។ បទឧក្រិដ្ឋប្រល័យពូជសាសន៍គ្មានអាជ្ញាយុកាលឡើយ ។

**ហេតុនេះ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តច្បាប់ដែលមានបញ្ញត្តិដូចតទៅនេះ ៖**

**មាត្រា ១.**_ ដាក់ក្រុម « កម្ពុជាប្រជាធិបតេយ្យ » និងកម្លាំងយោធារបស់ខ្លួនឱ្យនៅក្រៅច្បាប់ ។

**មាត្រា ២.**_ ចាប់ពីថ្ងៃដែលច្បាប់នេះចូលជាធរមាន ជនទាំងឡាយណាដែលជាសមាជិកអង្គការនយោបាយនិងជាកម្លាំងយោធារបស់ក្រុម « កម្ពុជាប្រជាធិបតេយ្យ » ត្រូវចាត់ទុកជាជនល្មើសនឹងរដ្ឋធម្មនុញ្ញនិងជាជនល្មើសនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

សមាជិកអង្គការនយោបាយឬកម្លាំងយោធារបស់ក្រុម « កម្ពុជាប្រជាធិបតេយ្យ » គឺត្រូវកំណត់បានតែជនទាំងឡាយណាដែលឱ្យបញ្ជា សមគំនិតឬចូលប្រឡូកដោយផ្ទាល់ក្នុងជម្លោះដោយអាវុធ ក្នុងទិសដៅបំរើនយោបាយរបស់ក្រុម « កម្ពុជាប្រជាធិបតេយ្យ » ។

ជនខាងលើនេះ មិនត្រូវកំណត់បានដល់ជនទាំងឡាយដែលជាក្រុមគ្រួសារឬជាជនដែលរស់នៅក្រោមការគៀបសង្កត់របស់ក្រុម « កម្ពុជាប្រជាធិបតេយ្យ » ឡើយ ។

**មាត្រា ៣.**_ សមាជិកអង្គការនយោបាយនិងកម្លាំងយោធារបស់ក្រុម « កម្ពុជាប្រជាធិបតេយ្យ » ឬជនណាដែលបានប្រព្រឹត្តបទឧក្រិដ្ឋធ្វើមនុស្សឃាតដោយចេតនា ចាប់បង្ខំនារីរំលោភសេពសន្ថវៈ ប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ បំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈនិងឯកជន ។ល។ ត្រូវផ្ដន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៤.**– សមាជិកនៃរដ្ឋការនយោបាយនិងកម្លាំងយោធារបស់ក្រុម « កម្ពុជាប្រជាធិបតេយ្យ » ឬជនណាដែលបានប្រព្រឹត្តអំពើ :

- ធ្វើសកម្មភាពអបគមន៍
- បំផ្លាញរាជរដ្ឋាភិបាល
- បំផ្លាញអង្គការនៃអំណាចសាធារណៈ
- ញុះញង់ឬបង្ខំពលរដ្ឋឱ្យកាន់អាវុធប្រឆាំងនឹងអាជ្ញាធរសាធារណៈ ត្រូវចាត់ទុកជាជនឧក្រិដ្ឋប្រឆាំងនឹងសន្តិសុខក្នុងប្រទេស ហើយត្រូវផ្តន្ទាទោសដាក់គុកពី ២០ ឆ្នាំទៅ ៣០ ឆ្នាំ ឬអស់មួយជីវិត ។

**មាត្រា ៥.**– ច្បាប់នេះអនុគ្រោះទុកពេល ៦ ខែ ក្រោយពីចូលជាធរមាន ឱ្យជនជាសមាជិកអង្គការនយោបាយឬជាកម្លាំងយោធានៃក្រុម « កម្ពុជាប្រជាធិបតេយ្យ » វិលត្រលប់មករួមរស់ក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនយកទោសពៃរ៍ចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត ។

**មាត្រា ៦.**– ចំពោះមេដឹកនាំនៃក្រុម « កម្ពុជាប្រជាធិបតេយ្យ » មិនអាចមានការអនុគ្រោះ ដូចមានចែងក្នុងច្បាប់នេះឡើយ ។

**មាត្រា ៧.**– ព្រះមហាក្សត្រទ្រង់អាចបន្ធូរបន្ថយទោសឬលើកលែងទោសតាមព្រះរាជសិទ្ធិដែលមានចែងក្នុងមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញ ។

**មាត្រា ៨.**– ក្រោយពីច្បាប់នេះចូលជាធរមានភ្លាម ទ្រព្យសម្បត្តិទាំងឡាយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុម « កម្ពុជាប្រជាធិបតេយ្យ » ឬរបស់ជនល្មើសផ្សេងទៀតហើយដែលបានមកពីការបំបែកកាត់កាប់ទឹកដីមួយផ្នែកនៃព្រះរាជាណាចក្រកម្ពុជាដោយរំលោភច្បាប់ និងយកធនធានធម្មជាតិរបស់ប្រជាជាតិទៅធ្វើអាជីវកម្ម ទ្រព្យសម្បត្តិទាំងឡាយនោះ នឹងត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ទោះបីស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬស្ថិតនៅក្រៅប្រទេស ។

**មាត្រា ៩.**– ជនណាមួយដែលយកច្បាប់នេះទៅរំលោភសិទ្ធិប្រជាពលរដ្ឋដោយធ្វើការគំរាមកំហែង ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួន ការធ្វើទារុណកម្មឬរំលោភលើលំនៅស្ថានមិនត្រឹមត្រូវ ត្រូវផ្តន្ទាទោស ដាក់គុកពី ពីរឆ្នាំទៅ ប្រាំឆ្នាំ ។

អ្នកផ្តល់ពត៌មានមិនពិត អ្នកធ្វើសាក្សីក្លែងក្លាយ អ្នកក្លែងបង្កើតភស្តុតាងដើម្បីចំណេញផលប្រយោជន៍នៃការយកច្បាប់នេះទៅរំលោភសិទ្ធិប្រជាពលរដ្ឋត្រូវផ្តន្ទាទោសដាក់គុកពី ពីរឆ្នាំទៅ ប្រាំឆ្នាំ ។

ប្រជាពលរដ្ឋរងគ្រោះដោយអយុត្តិធម៌ មានសិទ្ធិប្តឹងតវ៉ាទារសំណង ដើម្បីជួសជុលការខូចខាតដែលបង្កើតឡើងពីការរំលោភសិទ្ធិខាងលើ ។

<u>មាត្រា ១០</u> - ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៥
ចុងព្រះនាមនិងនាមត្រកូលរាជបញ្ញាត់
ប្រមុខរដ្ឋស្តីទី

ជា ស៊ីម

---

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២

ធរោត្តម រណឫទ្ធិ | ហ៊ុន សែន

បានបង្គំទូលថ្វាយនិងជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី១ និងទី២
សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សុខ អាន | វេង សិរីវុឌ្ឍ